ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ...០១៤/១៧...ក.ប/ស.ជ.ណា.ក.ប.ក

# សេចក្តីជូនដំណឹង
## ស្តីពី
## ការផ្តល់ប្រាក់ឈ្នួល និងប្រាក់បំណាច់ប្រចាំថ្ងៃចំពោះកម្មករនិយោជិតជាស្ត្រី សម្រាប់រយៈពេលនៃការឈប់សម្រាកមាតុភាព

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់កម្មករនិយោជិត ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថានទាំងអស់ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ឱ្យបានជ្រាបថា យោងតាម មាត្រា១៨២ និងមាត្រា១៨៣ នៃច្បាប់ស្តីពីការងារ កម្មករនិយោជិតជាស្ត្រីត្រូវមានសិទ្ធិឈប់សម្រាក ៩០ថ្ងៃ ដើម្បីសម្រាលកូន ហើយកម្មករនិយោជិតជាស្ត្រីដែលធ្វើការក្នុងសហគ្រាស គ្រឹះស្ថានបានយ៉ាងតិច ០១ឆ្នាំ រៀងមក មានសិទ្ធិត្រូវទទួលបានប្រាក់ឈ្នួលពាក់កណ្តាល គិតទាំងប្រាក់បន្ទាប់បន្សំផង ក្នុងរយៈពេលនៃ ការឈប់សម្រាកនេះ។

បន្ថែមលើនេះ កម្មករនិយោជិតនៃសហគ្រាស គ្រឹះស្ថានដែលជាសមាជិករបស់បេឡាជាតិរបបសន្តិសុខ សង្គម ផ្នែកថែទាំសុខភាព ត្រូវទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ ដូចមានចែងក្នុងប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្តីពីតាវកាលិកថែទាំសុខភាព។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា កម្មករនិយោជិត ម្ចាស់ នាយក សហគ្រាស គ្រឹះស្ថានទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៧
រដ្ឋមន្ត្រី

អ៊ិត សំហេង

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារៈ(០២៣) ៨៨ ២៧ ៦៩